ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
*********

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី
សំណុំរឿងលេខ១៥៤
ចុះថ្ងៃទី២២ខែឧសភាឆ្នាំ១៩៩៨
សាលដីកា
លេខ ៣១
ចុះថ្ងៃទី២៣ខែកុម្ភៈឆ្នាំ១៩៩៩

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅ ៖

១_ ឯកឧត្តម ឌិត មុន្ទី ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២_ លោក ប៉ែន ស៊ុន ជាចៅក្រម
៣_ លោក វៀល មួន ជាចៅក្រម_របាយការណ៍
៤_ លោក ជីវ កេង ជាចៅក្រម
៥_ លោក ស៊ិន នឹម ជាចៅក្រម

ក្រឡាបញ្ជី
លោក សុង ម៉ៅ
តំណាងមហាអយ្យការ
លោក ជួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧៣ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះហែម ឈន អាយុ៤៩ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅភូមិ៣ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនៈគិរី ។ ឪពុកឈ្មោះប្រាក់ ពឹក "រ" ម្តាយឈ្មោះសៀក "ស" ប្រពន្ធឈ្មោះទំ អ៊ាន មានកូន៦នាក់ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះឆន អៀម ភេទស្រី អាយុ៦៥ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅភូមិ១ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនៈគិរី ។ ឪពុកឈ្មោះឆន "ស" ម្តាយឈ្មោះគីម ទូច "ស" ប្តីឈ្មោះ សេង មានកូន២នាក់ ។

<u>កម្មវត្ថុបណ្តឹង</u> ប្តឹងទាមទារដី ។

បានឃើញបណ្ដឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៨ របស់ឈ្មោះហែម ឈន ប្ដឹងមិនសុខចិត្តនិងសេចក្ដីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៥៤ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៨របស់តុលាការកំពូល។

ពាក្យបណ្ដឹងចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៥របស់ឈ្មោះឆន អៀម ប្ដឹងពីឈ្មោះហែម ឈន រំលោភលើដីធ្លីកម្មសិទ្ធិរបស់ខ្លួនដោយសំអាងហេតុថា ឈ្មោះហែម ឈន ក្រោយពីមានការព្រមព្រៀងជាមួយឈ្មោះ សុង ហើយក៏សង់ផ្ទះលើដីរបស់ខ្លួន ។ ខ្លួនសំណូមពរទាមទារដីរបស់ខ្លួនព្រោះដីនេះខ្លួនមានប័ណ្ណកម្មសិទ្ធិរួចហើយ ។

បានឃើញសាលក្រមលេខ០៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦ របស់តុលាការខេត្តរតនៈគីរី ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ៖

១- ទទួលស្គាល់ពាក្យបណ្ដឹងរបស់អ្នកស្រីឆន អៀម ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២- លោក ឆន់ ប៊ុនសុង ត្រូវចេញប្រាក់ចំនួន១០០.០០០៛(ដប់ម៉ឺនរៀល) ឱ្យទៅលោក ហែម ឈន វិញ ។

៣- លោកហែម ឈន ត្រូវរុះផ្ទះចេញពីដីដែលមានទំនាស់ រួចប្រគល់ឱ្យទៅអ្នកស្រីឆន អៀម កាន់កាប់ជាកម្មសិទ្ធិស្របច្បាប់តទៅ ។

៤- សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូក្ដី ។

៥- បើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍រយៈពេល២ខែគិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៧៣ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៧ ប្ដឹងមិនសុខចិត្តលើសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៨ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១១-៧-១៩៩៦ របស់ដើមបណ្ដឹងឧទ្ធរណ៍ឈ្មោះហែម ឈន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុសនិងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ០៣ ចុះថ្ងៃទី២៨-៥-១៩៩៦ របស់តុលាការខេត្តរតនៈគីរី ទុកជាបានការ ។

៣- សំរេចកាត់យកប្រាក់ប្រដាប់ក្ដីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយគឺពន្ធចុះបញ្ជីក្ដីនិងពន្ធហ៊ឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល និងលើអាជ្ញាធរតុលាការ៥.០០០រៀល ។

- កាលបើសាលដីកានេះចូលជាស្ថាពរហើយ បង្គាប់ឱ្យឈ្មោះហែម ឈន បង់ពន្ធសមាមាត្រ១% លើប្រាក់១០០.០០០រៀល ។ ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋ៨០% និងដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៤- សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។

- សំរេចបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី១២-៣-៩៨របស់លោកហែម ឈន ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាការពាររបស់ឈ្មោះហែម ឈន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៨ ។

បានឃើញសារណាតបរបស់ឈ្មោះ ឆន អៀម ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៨ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយករណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ សាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបានតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់សារណារបស់ឈ្មោះហែម ឈន នៅពេលជំនុំជំរះ ។

បានស្តាប់សារណាតបរបស់ឈ្មោះឆន អៀម នៅពេលជំនុំជំរះ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ៥៧ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៨របស់លោកហែម ឈន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាការដែលលោក ហែម ឈន អះអាងថា ប័ណ្ណសំគាល់សិទ្ធិលេខC១-១៧៥ ចុះថ្ងៃទី១៤-១-៩៤របស់លោកធន់ ប៊ុនហៀង ជាប័ណ្ណកម្មសិទ្ធិក្លែងបន្លំនោះ ពុំមានភស្តុតាងណាបញ្ជាក់គួរឱ្យជឿបានឡើយ ហើយការសំអាងទៅលើគណៈកម្មការវាស់វែងដែលថា ក្នុងការវាស់ដីឱ្យលោកធន់ ប៊ុនហៀង គឺធ្វើចាប់ពីបារ៉ែតទៅក្រោយនោះ ក៏ជាការពុំត្រឹមត្រូវដែរ ពីព្រោះថាពាក្យសុំចុះថ្ងៃទី

១៥_៧_៩០របស់លោកធន់ ប៊ុនហៀង បានកំណត់ព្រំខាងលិច ទល់នឹងថ្នល់ដែរ ដូច្នេះដីដែលលោក ហែម ឈន សង់ផ្ទះនោះ ជាដីដែលស្ថិតក្នុងប័ណ្ណកម្មសិទ្ធិលេខC១_១៧៥ ប្រាកដមែន ។

_ យល់ឃើញថាការដែលតុលាការខេត្តរតនះគីរីក៏ដូចសាលាឧទ្ធរណ៍ដែរ ដែលសំរេចឱ្យលោក ធន់ ប៊ុនស៊ុង សងប្រាក់ចំនួន១០០.០០០រៀល ទៅលោកហែម ឈន នោះជាការខុសឆ្គង ពីព្រោះ ថា សាលាជំរះក្តីទាំងពីរនេះពុំបានចាត់របៀបបញ្ចូលលោកធន់ ប៊ុនស៊ុង មកក្នុងរឿងក្តីនេះផង និង ពុំមានពាក្យសុំពីគូក្តីណាមួយផង ។

_ យល់ឃើញថា គូភាគីនៃរឿងក្តីនេះបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការ កំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ លោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

_ យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២_៣_៩៨ ដែលសំរេចសេចក្តី មកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ លើកលែងចំណុចទី២ នៃសាលក្រមលេខ០៣ ចុះថ្ងៃទី២៨_៥_៩៨ របស់តុលាការខេត្តរតនះគីរី ដែលត្រូវទុកជាមោឃៈ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីកំបាំងមុខគូក្តីប៉ុន្តែចាត់ទុកជាចំពោះមុខ

១_ ទទួលបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី១២_៣_៩៨របស់លោកហែម ឈន ទុកជាត្រឹមត្រូវ តាមទម្រង់និងគតិច្បាប់ខ្វះ ។

២_ តម្កល់សាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២_៣_៩៨ របស់សាលាឧទ្ធរណ៍ទុកជាបាន ការ លើកលែងចំណុចទី២ នៃសាលក្រមរដ្ឋប្បវេណីលេខ០៣ ចុះថ្ងៃទី២៨_៥_៩៦ របស់តុលាការខេត្ត រតនះគីរី ដែលត្រូវទុកជាមោឃៈ ។

៣_ បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៥៤ ចុះថ្ងៃទី២២_៥_៩៨របស់តុលាការកំពូលទៅសាលា ឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញត្រង់ចំណុចទី២នៃសាលក្រមរដ្ឋប្បវេណីលេខ០៣ ចុះថ្ងៃទី២៨_៥_៩៦ របស់តុលាការខេត្តរតនះគីរី ។

៤_ វិបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀលដែលលោកហែម ឈន បានបង់រួចហើយគឺ ៖

_ ពន្ធចុះបញ្ជីក្តីនិងពន្ធហ៊ឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

_ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

បង្គាប់ឱ្យលោក ហែម ឈន បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីទំនាស់ ។

៥_ សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩ ។

៧